# ដំណាំគម្របដីសណ្តែកផ្កា សម្រាប់ចម្ការម្រេច



**លោក នុត ភី ដាំម្រេច ១៤០០ ជន្លង់**
កសិករ ភូមិសង្កែចាស់
ឃុំមេមង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ
« ខ្ញុំសង្កេតឃើញថា ដីចម្ការដែលជម្រះ ឬបាញ់ថ្នាំយូរទៅ កាន់តែខ្សោះជីជាតិ។ ពេលមានដំណាំគម្របដី វារក្សាសំណើមដីបានល្អ មិនហែងដូចជាដីដែលជម្រះស្មៅចេញ។ យើងអាចដាំសណ្តែកផ្កាក្នុងម្រេចបានគ្រប់ពេល ប៉ុន្តែនៅរដូវវស្សាល្អជាង»។ ការកាត់គម្របដីមិនចំណាយច្រើនដូចកាត់ស្មៅចង្រៃទេ»



**លោក លីម លាង ដាំម្រេច ១២០០ ជន្លង់**
កសិករ ភូមិជាង ឃុំមេមង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ
« វិធីសាស្រ្តនេះបានជួយខ្ញុំសន្សំការចំណាយលើការស្រោចស្រព ដោយកាត់បន្ថយពីស្រោច ៣ ថ្ងៃម្តង ទៅ ៦ ថ្ងៃម្តងនៅរដូវប្រាំង ព្រោះវាជួយរក្សាសំណើមដី ហើយទឹកជ្រាបបានលឿន។ លើសពីនេះវាបង្កើតជីវចម្រុះក្នុងដីបានច្រើន ដូចជាជន្លេន ហើយដីមានសភាពធូរល្អ។ វាក៏មានប្រយោជន៍ដល់សត្វចញ្ចឹមដូចជាមាន់ វាអាចស៊ីចំណីដោយផ្ទាល់ក្នុងចម្ការ។ ចំណែកម្រេចវិញ ក្រោយពេលបូតផ្លែ វាមានកម្លាំងលូតលាស់។»



**លោក អេង ហ៊ន់ ដាំម្រេច ២០០០ ជន្លង់**
កសិករ ភូមិរអូរតាញ្ញាណ ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ។
«ខ្ញុំធ្វើស្មៅជាប្រចាំ ខែវស្សាត្រូវកាត់ស្មៅ និងបាញ់ថ្នាំក្នុងរដូវប្រាំង។ វាមិនល្អសម្រាប់ចម្ការ និងសុខភាពរបស់យើងផងដែរ។ ដំណាំគម្របដីអាចគ្រប់គ្រងស្មៅចង្រៃបានដល់ ៩០% ហើយត្រូវការការថែរទាំងតិច បើប្រៀបជាមួយនឹងស្មៅចង្រៃ។ »



**លោក សាំង ថន ដាំម្រេច ៣៣០០ ជន្លង់**
កសិកររស់នៅភូមិគគីជើង ឃុំគគីរ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ
« ការដាំដំណាំគម្របដីគឺពិបាកថែរក្នុងពេលដំបូង ប៉ុន្តែងាយស្រួលវិញពេលវាដុះលុបជិត។ ខែវស្សាវាជួយដីចម្ការកុំអោយហូរច្រោះ និងមិនចាំបាច់កាត់ទេ ក្នុងរដូវប្រាំង។»

CAMBODIA CLIMATE CHANGE ALLIANCE

គម្រោងចម្ការដំណាំវៃឆ្លាតធន់នឹងអាកាសធាតុ

## គុណសម្បត្តិ

- បង្កើនមមោគដី រក្សាសំណើមដីក្នុងចម្ការ ធ្វើឱ្យដីធូរល្អ
- ចំណេញពលកម្មសម្អាតស្មៅចង្រៃ
- ចំណេញទឹកស្រោចស្រពក្នុងខែប្រាំងរហូតដល់ ៥០%
- កាត់បន្ថយការហូរច្រោះដីចម្ការ ជាពិសេសចម្ការលើដីជម្រាល

## តម្រូវការអនុវត្តន៍

- ត្រូវការគ្រប់គ្រងដោយការកាត់ដើម ២ ទៅ ៣ ដងក្នុងមួយឆ្នាំ
- ការថែទាំសម្អាតស្មៅចង្រៃនៅដំណាក់កាល ២ ខែ ដំបូង